# អាទិត្យទី១៩ នៃរដូវធម្មតា
# ព្រះសហគមន៍សន្តីម៉ារីញញឹម ចំការទៀន
# ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២១

**"សេរីភាព"**

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ នៅពេលយើងស្តាប់ព្រះបន្ទូលនីមួយៗ ហាក់បីដូចជាយើងស្តាប់ព្រះជាម្ចាស់ដែលកំពុងមានព្រះបន្ទូលមកយើង កុំឲ្យយើងធ្លាក់ទឹកចិត្ត កុំឲ្យយើងបាត់សេចក្តីសង្ឃឹមនៅក្នុងដួងចិត្តរបស់យើង។ សូមចាប់អារម្មណ៍សារជាថ្មី នៅក្នុងអត្ថបទទី១យើងឃើញព្យាការី អេលី កំពុងបាត់បង់សេចក្តីសង្ឃឹម ដែលព្រះមហាក្សត្រីកំពុងរកមធ្យោបាយដើម្បីប្រហារជីវិតរបស់គាត់។ គាត់ត្រូវការគេចឆ្ងាយពីទីក្រុង គាត់នៅសល់តែពាក្យមួយឃ្លា "**បពិត្រព្រះអម្ចាស់ ទូលបង្គំទ្រាំទ្រលែងបានទៀតហើយ ឥឡូវនេះសូមដកជីវិតទូលបង្គំចុះ**" គាត់បាត់បង់សេចក្តីសង្ឃឹមអស់ហើយ គាត់គិតតែទៅវាលរហោស្ថានដើម្បីទៅស្លាប់។ ប៉ុន្តែ ព្រះជាម្ចាស់មិនព្រម និងគាត់បានទទួលកម្លាំងសារជាថ្មីនៅពេលព្រះជាម្ចាស់មានព្រះបន្ទូលដល់គាត់ថា "**ចូរក្រោកឡើងបរិភោគទៅ ត្បិតលោកត្រូវធ្វើដំណើរយ៉ាងឆ្ងាយ**"។ នេះជាព្រះបន្ទូលសម្រាប់យើងសព្វថ្ងៃ ឲ្យយើងដឹងថាកុំឲ្យយើងបាត់បង់សេចក្តីសង្ឃឹម។

ជីវិតរបស់យើងសព្វថ្ងៃមានឧបសគ្គជាច្រើន ប៉ុន្តែមានឧបសគ្គយ៉ាងណាក៏ដោយក៏យើងដឹងថានៅក្នុងជំនឿដែលយើងទទួលពីព្រះជាម្ចាស់ យើងមានសេចក្តីសង្ឃឹមដើម្បីទៅមុខ "**ចូរក្រោកឡើងដើម្បីទៅមុខទៅ ត្បិតត្រូវធ្វើដំណើរយ៉ាងឆ្ងាយ**"។ ជីវិតរបស់យើងត្រូវបន្តធ្វើដំណើរយ៉ាងឆ្ងាយ ដោយទទួលកម្លាំងពីព្រះជាម្ចាស់ផ្ទាល់។ នៅក្នុងកម្លាំងដែលយើងទទួលពីព្រះជាម្ចាស់ យើងរកឃើញរបៀបដែលយើងត្រូវតែរស់នៅពីមួយថ្ងៃទៅមួយថ្ងៃ ដូចយើងបានស្តាប់នៅក្នុងអត្ថបទរបស់សន្តប៉ូលដែលបានប្រៀនប្រដៅយើងនៅថ្ងៃនេះ។ យើងត្រូវមានចិត្តសប្បុរស ចេះអាណិតមេត្តាដល់គ្នាទៅវិញទៅមក ត្រូវប្រណីសន្តោសគ្នាទៅវិញទៅមក ដូចព្រះជាម្ចាស់បាន

ប្រណីសន្តោសបងប្អូនដោយសារព្រះគ្រីស្តដែរ។ ត្រូវការយកគម្រប់តាមព្រះជាម្ចាស់ ព្រោះបងប្អូនជាបុត្រធីតាដ៏ជាទីស្រឡាញ់របស់ព្រះជាម្ចាស់ "**ត្រូវតែរស់នៅដោយមានចិត្តស្រឡាញ់ដូចព្រះយេស៊ូបានស្រឡាញ់យើង ដោយបានបូជាព្រះជន្មសម្រាប់យើងទុកជាដង្វាយថ្វាយព្រះជាម្ចាស់ និងទុកជាសញ្ញាបូជាដែលគាប់ព្រះហឫទ័យព្រះអង្គផង**"។

ពិតមែន នៅក្នុងរបៀបដែលលោក ប៉ូល និយាយដល់គ្រីស្តបរិស័ទនៅទីក្រុង អេភេសូ ហាក់បីដូចជានិយាយដល់យើងថ្ងៃនេះ។ ដើម្បីធ្វើដំណើរទៅមុខនៅលើផែនដីនេះ យើងត្រូវតែមានចិត្តសប្បុរស អាណិតមេត្តា ស្រឡាញ់គ្នា ប្រណីសន្តោស ដោយសារយើងជាបុត្រធីតារបស់ព្រះជាម្ចាស់។ យើងរៀងៗខ្លួនបានទទួលតម្លៃថ្លៃថ្នូរស្មើៗគ្នា យើងរៀងៗខ្លួនបានទទួលសិទ្ធិសេរីភាពស្មើៗគ្នា យើងរៀងៗខ្លួនយើងមានតម្លៃស្មើៗគ្នានៅក្នុងព្រះហស្តព្រះជាម្ចាស់ ដែលបានបង្កើតយើងជាបុត្រធីតារបស់ព្រះអង្គ។ យើងអាចធ្វើដំណើរដោយសារយើងដឹងថា យើងមានព្រះយេស៊ូដែលមានព្រះបន្ទូលថ្ងៃនេះសំខាន់ណាស់ "**ខ្ញុំនេះហើយ ជាអាហារដែលមានជីវិតចុះពីស្ថានបរមសុខ អ្នកណាបរិភោគអាហារនេះនឹងរស់នៅអស់កល្បជានិច្ច អាហារដែលខ្ញុំឲ្យនោះគឺរូបកាយខ្ញុំផ្ទាល់ ដែលត្រូវបូជាសម្រាប់ឲ្យមនុស្សលោកមានជីវិត**"។ ពិតមែនអត្ថបទនីមួយៗថ្ងៃនេះ ណែនាំឲ្យយើងរកឃើញអត្ថន័យនៃជីវិតរបស់យើង រកឃើញសេចក្តីសង្ឃឹមនៅក្នុងជីវិតរបស់យើងជាប្រចាំ។

បងប្អូនជាទីស្រឡាញ់ នៅក្នុងជីវិតរបស់យើងយើងពិបាកពិតមែន ប៉ុន្តែនៅក្នុងជីវិតបងប្អូនឯទៀតៗក៏ពិបាកដែរ។ ពីម្សិលមិញខ្ញុំបានចូលរួមនៅក្នុងសិក្ខាសាលាពីចម្ងាយ ដើម្បីកសាងសុខសន្តិភាពនៅក្នុងប្រទេសមីយ៉ាន់ម៉ា។ ប្រទេសមីយ៉ាន់ម៉ា មិនឆ្ងាយពីប្រទេសកម្ពុជាយើងប៉ុន្មានទេ ពីប៉ុន្មានខែកន្លងមកមានសង្គ្រាមស៊ីវិល ណែនាំឲ្យប្រជាជនមួយចំនួនបាត់បង់សិទ្ធិសេរីភាពទាំងអស់ ណែនាំឲ្យប្រជាជនមួយចំនួនបាត់បង់អាយុជីវិត ដែលប្រើអំពើហិង្សាដើម្បីបិទសំឡេង និងបិទសិទ្ធិសេរីភាពរបស់ពួកគាត់។ ប្រជាជនមួយចំនួន នៅពេលនេះកំពុងអស់សង្ឃឹម មិនមែនដោយសារតែជំងឺកូវីដ-១៩តែប៉ុណ្ណឹង ប៉ុន្តែដោយសារតែបរិយាកាសដែលកំពុងកើតឡើងនៅក្នុងប្រទេសមីយ៉ាន់ម៉ា។ ម្សិលមិញ ជាមួយយុវជន ជាមួយមនុស្សពេញវ័យ នៅក្នុងទ្វីបអាស៊ីរបស់យើងពីប៉ុន្មានប្រទេស ប្រទេសកម្ពុជាយើងមាន២៥នាក់ ពីប្រទេសភីលីពីន ប្រទេសនេប៉ាល់ ប្រទេសថៃ ប្រទេសម៉ាឡេស៊ី ប្រទេសឥណ្ឌូនេស៊ី ហើយក៏មានមកពីប្រទេសមីយ៉ាន់ម៉ាដែរ។ យើងបានជួបជុំគ្នាពីចម្ងាយ ដើម្បីគិតពិចារណា **តើយើងអាចធ្វើអ្វីខ្លះ ដើម្បីធ្វើដំណើរជាមួយប្រជារាស្ត្រនៅលើទឹកដីនៃប្រទេសមីយ៉ាន់ម៉ា?** យើងដឹងថា យើងមិនអាចទៅប្រទេសមីយ៉ាន់ម៉ាបានទេ

យើងជាយុវជន-យុវនារី យើងមានកម្លាំង យើងមានអំណាចពីណា ដើម្បីទៅប្រឆាំងជាមួយអ្នកដឹកនាំដ៏ធំ? ប៉ុន្តែយ៉ាងតិច នៅពេលយើងជួបជុំគ្នាដូចម្សិលមិញ យើងបានយល់ថា ពិតមែនយើងជាគ្រួសារតែមួយ។ ពិតមែន យើងមានអំណាចមួយដ៏ពិសេស ដែលព្រះជាម្ចាស់មានព្រះបន្ទូលពីម្សិលមិញដែរ "**ប្រសិនបើយើងមានជំនឿ យ៉ាងតិចបំផុតយើងអាចលើកភ្នំមួយពីកន្លែងមួយទៅកន្លែងមួយ**" នៅពេលនេះយើងឃើញថា យើងមានកម្លាំងមកពីជំនឿ និងជាពិសេសកម្លាំងមកពីអធិដ្ឋាន។ ដូច្នេះ យើងមិនអាចធ្វើអ្វីប៉ុន្មានទេ តែយ៉ាងតិចក៏យើងអាចអធិដ្ឋានរួមគ្នា ដើម្បីឲ្យប្រទេសមីយ៉ាន់ម៉ា និងប្រទេសនីមួយៗនៅលើផែនដីនេះរកឃើញសេចក្ដីសុខសាន្ត។ អធិដ្ឋានដើម្បីឲ្យប្រជាជននៅលើផែនដីនេះ អាចមានសិទ្ធិសេរីភាពនៅក្នុងការសម្រេចចិត្ត ដើម្បីរៀបចំជីវិតជាប្រចាំ។

សិទ្ធិសេរីភាព មកពីព្រះជាម្ចាស់ដែលណែនាំឲ្យយើងទៅជាបុត្រធីតារបស់ព្រះអង្គ។ ប៉ុន្តែ សិទ្ធិសេរីភាពមកពីរបៀបដែលយើងខិតខំរស់នៅក្នុងសេចក្ដីពិតពីមួយថ្ងៃទៅមួយថ្ងៃ យើងនឹកឃើញព្រះបន្ទូលរបស់ព្រះយេស៊ូ "**អ្នកណារស់នៅតាមសេចក្ដីពិត អ្នកនោះពោរពេញដោយសេរីភាពដ៏ពិតប្រាកដ**"។ សេរីភាពរបស់យើងនៅមាន នៅពេលយើងចេះគោរពគ្នាទៅវិញទៅមក ប្រសិនបើយើងរស់នៅក្នុងភាពអាត្មានិយម ដែលមិនចេះនឹកឃើញដល់បងប្អូនឯទៀតៗ ដោយគិតថាយើងធ្វើតាមចិត្ត។ ប៉ុន្តែ សេរីភាពមិនមែនធ្វើតាមចិត្ត សេរីភាពធ្វើដូចម្ដេចដើម្បីរស់នៅតាមរបៀបព្រះយេស៊ូដែលជាគំរូរបស់យើង ដើម្បីឱ្យយើងចេះស្រឡាញ់គ្នាទៅវិញទៅមក។ ដូចយើងបានស្ដាប់នៅក្នុងអត្ថបទទី២ ដើម្បីឱ្យយើងចេះគោរពគ្នាទៅវិញទៅមក។ ដោយដឹងថា សេរីភាពរបស់ខ្ញុំចាប់ផ្ដើមនៅពេលបងប្អូនឯទៀតៗទទួលការគោរព ទទួលការរាប់អាន ទទួលសេរីភាពដោយសារខ្ញុំចេះមើលគាត់ដូចជាបងប្អូនបង្កើត។

ខ្ញុំមានសេរីភាព ដើម្បីដឹកនាំជីវិតរបស់ខ្ញុំពីមួយថ្ងៃទៅមួយថ្ងៃ ដោយជ្រើសរើសការសិក្សាដែលយើងចង់បាន ដោយជ្រើសរើសថ្នាំដែលយើងចង់ប្រើដើម្បីការពារខ្លួនពីជំងឺនានា។ ប៉ុន្មានថ្ងៃកន្លងមក យើងបានស្ដាប់អង្គការសុខភាពពិភពលោកដែលបាននិយាយថា "**កុំបង្ខំប្រជាជនឱ្យទទួលវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ផ្ទុយទៅវិញសូមបំភ្លឺប្រជាជនឱ្យគេយល់អំពីអត្ថប្រយោជន៍នៃវ៉ាក់សាំង ឱ្យគេយល់អំពីអត្ថប្រយោជន៍សម្រាប់ជីវិតរបស់គេ និងសម្រាប់ជីវិតរបស់បងប្អូនឯទៀតៗដែរ**"។ នៅពេលយើងបង្ខំយើងបាត់បង់សិទ្ធិសេរីភាព ប៉ុន្តែនៅពេលយើងបំភ្លឺដោយមនសិការយ៉ាងច្បាស់លាស់ ណែនាំឱ្យយើងយល់ផ្ទាល់ខ្លួនអ្វីដែលល្អសម្រាប់ខ្លួនខ្ញុំ។ ដោយសារព្រះជាម្ចាស់បានបង្កើតខ្ញុំ រូបកាយជាកម្មសិទ្ធិរបស់ខ្ញុំ ដូច្នេះគ្មាននរណាម្នាក់ដែលមានសិទ្ធិបង្ខំខ្ញុំឱ្យ

ទទួលថ្នាំ ឬទទួលអ្វីនៅក្នុងរូបកាយរបស់ខ្ញុំ។ ផ្ទុយទៅវិញ ខ្ញុំត្រូវការទទួលពន្លឺដើម្បីឲ្យមនសិការរបស់ខ្ញុំច្បាស់លាស់ដើម្បីសម្រេចចិត្ត ខ្ញុំចង់បានអ្វីខ្លះសម្រាប់ជីវិតរបស់ខ្ញុំ ដើម្បីរស់នៅក្នុងសង្គមបច្ចុប្បន្ននេះនៅក្នុងសុខដុមរមនា និងសេចក្ដីសុខសាន្ត។

ប៉ុន្មានថ្ងៃនេះ ខ្ញុំបានទៅមើលចម្ការយើងនៅភ្នំវល្លិ៍ ពេលខ្ញុំដើរខ្ញុំទៅដល់កន្លែងចិញ្ចឹមសត្វទា។ សត្វទាវារកឃើញប្រហោងនៅក្នុងរបង ដូច្នេះវាចេញពីស្រះទឹកដែលវានៅ ហើយវាទៅកន្លែងមួយទៀតដែលឃើញមានទឹកដែរ ប៉ុន្តែវាខុសកន្លែងហេតុនេះហើយខ្ញុំក៏ដេញវាចូលទៅកន្លែងដើម។ ជាធម្មតាសត្វទាពេលវាដើរ មានមេមួយក្បាលនាំមុខហើយកូនចៅទៅតាម ប៉ុន្តែលើកនេះប្លែកព្រោះថាមានមួយក្រុមទៅដល់កន្លែងដើម និងមួយក្រុមទៀតធ្វើដំណើរទៀតទៅដល់កន្លែងខុសច្បាប់។ ដូច្នេះ ណែនាំឱ្យខ្ញុំឆ្ងល់**តើវាមានមេពីរ?** សត្វទាចាប់ផ្ដើមមានសិទ្ធិសេរីភាពធ្វើតាមចិត្ត មានខ្លះភ័យវាទៅដល់កន្លែងដើម មានខ្លះទៅដល់កន្លែងខុសច្បាប់ ក្រោយមកខ្ញុំបណ្ដេញម្ដងទៀតទើបវាទៅកន្លែងដើមវិញ។ ជីវិតរបស់យើងមានសិទ្ធិសេរីភាព យើងមិនត្រូវដើរតាមគេ យើងត្រូវការធ្វើប្រយ័ត្ន របៀបដែលត្រឹមត្រូវគឺរបៀបដែលយើងសម្រេចចិត្តខ្លួនឯង ដោយទទួលពន្លឺនៅក្នុងដួងចិត្តរបស់យើង។

មនសិការជាអាទិភាព រៀងៗខ្លួនយើងមានមនសិការ រៀងៗខ្លួនយើងមានចិត្តគំនិតដើម្បីគិតដើម្បីសម្រេចចិត្ត។ ប៉ុន្តែ កុំឱ្យយើងរស់នៅក្នុងភាពងងឹត ប្រសិនបើយើងរស់នៅក្នុងភាពងងឹតយើងសម្រេចចិត្តខ្លួនឯងមិនបានទេ។ ដូច្នេះ យើងត្រូវការទទួលពន្លឺយ៉ាងច្បាស់លាស់ ស្រាវជ្រាវអានឯកសារ ស្ដាប់មនុស្សដែលមានសិទ្ធិនិយាយ (ជៀសវាងស្ដាប់ក្រុមអ្នកដែលផ្ដល់ព័ត៌មានមិនពិត)។ ប៉ុន្តែ យើងស្ដាប់ក្រុមគ្រូពេទ្យ ស្ដាប់ក្រុមដែលស្រាវជ្រាវយ៉ាងច្បាស់លាស់ ដើម្បីសម្រេចចិត្តសម្រាប់ជីវិតរបស់យើងផ្ទាល់ខ្លួន **តើយើងត្រូវការធ្វើអ្វីខ្លះ ដើម្បីរួមរស់នៅក្នុងសេចក្ដីសុខសាន្តដែលយើងត្រូវតែមាននៅលើផែនដីនេះ?** ទោះបីលោក អេលី បានទទួលដំណឹងពីព្រះជាម្ចាស់ថា "**ដំណើរជីវិតរបស់គាត់ក៏នៅឆ្ងាយទៀត**" ដំណើរជីវិតរបស់យើង យើងមិនដឹងថាឆ្ងាយប៉ុន្មាន ប៉ុន្តែអ្វីដែលសំខាន់គឺនៅក្នុងពេលវេលានេះ យើងយកចិត្តទុកដាក់ដើម្បីរៀបចំជីវិតយ៉ាងសមរម តាមព្រះហឫទ័យព្រះជាម្ចាស់ជានិច្ច។ ដោយដឹងថា យើងមានព្រះយេស៊ូដែលជាគំរូ យើងមានព្រះយេស៊ូដែលជាតម្រាប់ដើម្បីឱ្យធ្វើដំណើរនៅលើផែនដីនេះយ៉ាងច្បាស់លាស់។

បងប្អូនជាទីស្រឡាញ់ យើងបន្តអធិដ្ឋានដើម្បីឱ្យព្រះសហគមន៍របស់យើង យកចិត្តទុកដាក់រស់នៅតាមរបៀបដែលយើងត្រូវការរស់នៅសព្វថ្ងៃ។ ដោយអនុវត្តពកុំពការពារ កុំឱ្យយើងភ្លេចខ្លួន

ដោយសារខ្ញុំបានឃើញកន្លែងជាច្រើនចាប់ផ្ដើមភ្លេចខ្លួនអស់ហើយ កុំឱ្យស្ដាយក្រោយ កុំឱ្យយើងធ្វើតាមគេ ដោយសារបើគេធ្វើខុសនោះយើងនឹងធ្វើខុសដែរ។ យើងមានសិទ្ធិសេរីភាព ដើម្បីសម្រេចចិត្តអ្វីដែលត្រឹមត្រូវ អ្វីដែលមិនត្រឹមត្រូវ។ ដូច្នេះ យើងទទួលពន្លឺពីព្រះវិញ្ញាណដ៏វិសុទ្ធ យើងទទួលពន្លឺពីព័ត៌មានត្រឹមត្រូវដែលយើងស្ដាប់ពីមួយថ្ងៃទៅមួយថ្ងៃ ដើម្បីរើសផ្លូវត្រឹមត្រូវនៅក្នុងជីវិតរបស់យើង។ ដូច្នេះ មិនមែនដោយសារមនុស្សច្រើនគេធ្វើខុសយើងធ្វើខុសតាមគេ មិនមែនដោយសារមានមនុស្សយ៉ាងច្រើនដែលវង្វេងហើយយើងវង្វេងតាមគេ។ យើងត្រូវទៅជាបុត្រធីតារបស់ព្រះជាម្ចាស់ ដែលពោរពេញដោយសេរីភាពដោយសារយើងរស់នៅក្នុងសេរីភាព ដែលយើងទទួលពីព្រះជាម្ចាស់ ដែលយើងទទួលពីព្រះយេស៊ូ ដែលជាសេចក្ដីពិត ដែលជាផ្លូវ ដែលជាជីវិត ជីវិតអស់កល្បជានិច្ច។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ ឆ្មឹតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ